ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៦ រូប ៣៨៥៣

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម ម៉ម ខណ្ឌី ៣៨៥៤

២១-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥២ ស្តីពី ការតែងតាំងមន្ត្រីរាជការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ចំនួន ៣៦ រូប ៣៨៥៥

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ អង្គភាពស្ទង់ការប្រយុទ្ធនៃអគ្គសេនាធិការកងទ័ពប្រជាជនវៀតណាម ៣៨៥៩

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៤ ស្តីពី ការតែងតាំង ឯកឧត្តម នួន សុមេធ ជា អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ៣៨៦០

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៥ ស្តីពី ការបញ្ចប់មុខតំណែង ឯកឧត្តម ប្រាត់ ចំរើន ពី អនុរដ្ឋលេខាធិការ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទៅទទួលភារកិច្ចថ្មី ៣៨៦១

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីតំណាងក្រសួងស្ថាប័នប្រចាំការនៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចំនួន ០៨ រូប ៣៨៦២

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៧ ស្តីពី ការតែងតាំង លោក គង់ សេរីវុធ ជា ឧកញ៉ា ៣៨៦៣

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ប្រគេនចំពោះ ព្រះគ្រូ ម៉ិន ម៉ុនខេម ព្រះគ្រូចៅអធិការវត្តបុទុមគង្គា សង្កាត់ព្រែកលាប ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ៣៨៦៤

២២-៥-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៥១២/៤៥៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ សប្បុរសជន ចំនួន ០៤ រូប ៣៨៦៥

# II. រាជរដ្ឋាភិបាល

## ១. អនុក្រឹត្យ

២៣-៥-២០១២ -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពី ការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ ៣៨៦៦
២៤-៥-២០១២ -អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៣៨៧០
២១-៥-២០១២ -អនុក្រឹត្យលេខ ៦០០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៧២
២១-៥-២០១២ -អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣៨៧៣
២២-៥-២០១២ -អនុក្រឹត្យលេខ ៦០២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៣៨៧៥
២២-៥-២០១២ -អនុក្រឹត្យលេខ ៦០៣ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៣៨៧៦
២២-៥-២០១២ -អនុក្រឹត្យលេខ ៦០៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨៧៧
២២-៥-២០១២ -អនុក្រឹត្យលេខ ៦០៥ អនក្រ.តត ស្តីពី ការកែសម្រួលសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី ៣៨៧៩
២៣-៥-២០១២ -អនុក្រឹត្យលេខ ៦០៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨៨១
២៣-៥-២០១២ -អនុក្រឹត្យលេខ ៦០៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨៨២
២៤-៥-២០១២ -អនុក្រឹត្យលេខ ៦០៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៨៣
២៤-៥-២០១២ -អនុក្រឹត្យលេខ ៦០៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៨៤
២៤-៥-២០១២ -អនុក្រឹត្យលេខ ៦១០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៨៥
២៤-៥-២០១២ -អនុក្រឹត្យលេខ ៦១១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៨៦
២៤-៥-២០១២ -អនុក្រឹត្យលេខ ៦១២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨៨៧

## ២. សេចក្តីណែនាំរួម

២៨-៥-២០១២ -សេចក្តីណែនាំរួមលេខ ០២ សណន ស្តីពី តួនាទី ភារកិច្ច និង ការទទួលខុសត្រូវរបស់កងនគរបាលជាតិ កងរាជអាវុធហត្ថ និង កងយោធពលខេមរភូមិន្ទ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ នៅថ្ងៃអាទិត្យ ទី ០៣ ខែមិថុនា ឆ្នាំ ២០១២ ៣៨៨៨

# គ

## III-ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គីម អ៊ាង ខនស្រ្ទាក់សិន & អេនជីនារីង ៣៨៩១

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន សេដ្ឋា ដា៉រ៉ា ដាយអឹម៉ិុន ៣៨៩៣

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១០៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន បិន ឆៀន លី អ៊ិុមផត អិចផត ៣៨៩៥

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១១០ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ទីឡា ឆ្វេនធី-ម័ន ខូអិលធីឌី ៣៨៩៧

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១១២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស៊ី.ធី.ឌី អ៊ិុមផត អិចផត ៣៨៩៩

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១១៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេ អេ យូ គ្រេដ គ្រុប ៣៩០១

០២-៣-២០១១ -លិខិតបញ្ជាក់លេខ ១១១៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហៅស៍ អហ្វ ហ៊ិុលលីគ្រាន ៣៩០៣

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការចំនួន ០៦រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា និងជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយគ្រោះធម្មជាតិនានា នៅខេត្តព្រៃវែង

**នូវ**

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :
ឯកឧត្តមឧត្តមសេនីយ៍ឯក **សួរ ផន**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :
លោក **សៅ ចលក្ខណ៍**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :
១-លោក **សាយ ម៉ុនសៀន** ២-លោក **សែម សុខន្ធ**
៣-លោក **តួច សំអុន** ៤-លោកអនុសេនីយ៍ឯក **លាង សារិទ្ធ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១២០៥.៤៥៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២*

លេខ: ៤១១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

**ឯកឧត្តម ម៉ម ចណ្ណធី**

ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តកំពត

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រាជ.១២០៥.៤៥១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២*

លេខ: ៥១០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ៦ ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១៖** ត្រូវបានតែងតាំងមន្ត្រីរាជការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៖

១.ឯកឧត្តម **វង្ស៊ី វិស្សុត** ជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

២.ឯកឧត្តម **ជូ វិជិត្ត** ជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

៣.ឯកឧត្តម **ហ៊ាន សាហ៊ីប** ជាអនុប្រធាន និងទទួលបន្ទុកជាអគ្គលេខាធិការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

៤.ឯកឧត្តម មិុញ បានកុសល ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៥.ឯកឧត្តម កើត រិទ្ធ ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៦.ឯកឧត្តម កាន ច័ន្ទមេត្តា ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៧.ឯកឧត្តម រស់ សីលវ៉ា ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៨.ឯកឧត្តម ឈន សុភាព ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៩.ឯកឧត្តម ហាវ រតនៈ ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១០.ឯកឧត្តម ផាន់ ផល្លា ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១១.ឯកឧត្តម ជា ចាន់ទុំ ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១២.ឯកឧត្តម ហ៊ែល ចំរើន ជាអគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១៣.ឯកឧត្តម សេង ស្រេង ជាអគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១៤.ឯកឧត្តម អ៊ុង លុយណា ជាអគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១៥.ឯកឧត្តម ទេព ភិយ្យោរិទ្ធ ជាអគ្គលេខាធិការរងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

១៦.ឯកឧត្តម សៀក សុភ័ក ជាប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

១៧.ឯកឧត្តម ហៃ សុវុទ្ធា ជាប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសង្គមកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

១៨.ឯកឧត្តម **យក់ ប៊ុនណា** ជាប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច នៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

១៩.ឯកឧត្តម **អ៊ិន អេម** ជាប្រធានផ្នែកបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

២០.ឯកឧត្តម **ស៊ូ សុជាតិ** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

២១.ឯកឧត្តម **កៅ ថាច** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

២២.ឯកឧត្តម **សុខ ដារ៉ា** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អនុរដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

២៣.ឯកឧត្តម **អ៊ុំ សិទ្ធីរ៉ា** ជាជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

២៤.ឯកឧត្តម **គីម ផល្លា** ជាជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

២៥.ឯកឧត្តម **ឈុន សម្បត្តិ** ជាជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

២៦.ឯកឧត្តម **ប៉ែន ធីរុដ្ឋ** ជាជំនួយការឯកឧត្តម **វង្សី វិស្សុត** អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ជំនួសឯកឧត្តម **វ៉ា ស៊ីមសូរិយា** ដែលត្រូវបានបញ្ចប់ភារកិច្ច ដោយបានទទួលភារកិច្ចថ្មី) មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

២៧.ឯកឧត្តម **រស់ បរម** ជាជំនួយការឯកឧត្តម **ចាន់ សុធី** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** ត្រូវបានដំឡើងឋានៈមន្ត្រីរាជការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ :

១.ឯកឧត្តម **ជូ គីមឡេង** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

២.ឯកឧត្តម **ទូន ថាវរៈ** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

៣.ឯកឧត្តម **វង់ សណ្តាប់** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋមន្ត្រី* បន្ថែមលើមុខងារបច្ចុប្បន្ន

៤.ឯកឧត្តម **ចាន់ សុធី** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៥.ឯកឧត្តម **សុខ សារាវុឌ្ឍ** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *រដ្ឋលេខាធិការ* បន្ថែមលើមុខងារបច្ចុប្បន្ន

៦.ឯកឧត្តម **កែវ បេងវឡន៍** ជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

៧.ឯកឧត្តម **កើត សុធារ៉ា** ជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

៨.ឯកឧត្តម **ឈួន សិរិទ្ធិ** ជំនួយការប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន

៩.ឯកឧត្តម **ងួន មាស** ជំនួយការអនុប្រធានប្រចាំការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើ *អគ្គនាយក* បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល.១២០៥.៤៥៧

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១២*

លេខៈ ៤០៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១២

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១២/៤៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

**អង្គភាពស្នងការប្រយុទ្ធ នៃអគ្គសេនាធិការកងទ័ពប្រជាជនវៀតណាម**

មានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការជាមួយបញ្ជាការដ្ឋានកងទ័ពជើងគោក នៃកងយោធពលខេមរភូមិន្ទ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពារល.១២០៥.៤៥៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០១២*

លេខ: ៤៣៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០១២
អគ្គលេខាធិការ[illegible]ស្តីទីរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានតែងតាំងឯកឧត្តម នួន សុមេធ ជា អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៣៣.១២០៥.៤៦០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៤៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១ ... រាជរដ្ឋាភិបាល
... សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ឡាត់ ទំរ៉េង** ពីអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទៅទទួលភារកិច្ចថ្មី ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រគ.១២០៥.៤៦១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៣៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២
**អគ្គលេខាធិការរងនៃទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

ថ្នាក់ដឹកនាំនិងមន្ត្រីតំណាងក្រសួងស្ថាប័នប្រចាំការនៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
ចំនួន០៨រូប មានគុណបំណាច់ខ្ពស់និងស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-ឯកឧត្តម ស្វូន ស៊ីផាត់
២-ឧត្តមសេនីយ៍ត្រី កែវ មាស អត្តលេខ ០០១៩១៧
៣-ឯកឧត្តម ឈិត សារិទ្ធ
៤-ឯកឧត្តម ជា សំអាង
៥-ឯកឧត្តម ឡុង ឈាង

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

លោក គឹម ម៉េងអ៊ាង

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

ឧត្តមសេនីយ៍ត្រី ម៉ៅ សុខឡូនា អត្តលេខ ០៦៩០

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

លោក កែវ កណ្ណារិទ្ធ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩.១២០៥.៤៦២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៨៣៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible] រដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**តែងតាំង**

**លោក គង់ សេរីវុធ**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧ល.១២០៥.៤៦៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១២

លេខៈ ៤៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១២
អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ត្រាស់ព្រះរាជទាន

**នូវ**

## គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

**ប្រគេនចំពោះ**

## ព្រះគ្រូ ប៊ិន ប៊ុនខេម

ព្រះគ្រូចៅអធិការវត្តបុទុមគង្គា មានព្រះគុណបំណាច់និងស្នាព្រះហស្តល្អ ដោយបានបរិច្ចាគបច្ច័យចូលរួមក្នុងការកសាងសមិទ្ធផលជាច្រើនលើវិស័យព្រះពុទ្ធសាសនា នៅវត្តបុទុមគង្គា សង្កាត់ព្រែកលាប ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចបល.១២០៥.៤៦៤

លេខ: ៤៣៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២
អ...ការរដ្ឋទី១រាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៥១២/៤៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

សប្បុរសជន ចំនួន ០៤រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផល នានា នៅក្នុងវត្តពៅមុន្នីរស្មីទួលទ្រា ឃុំព្រែកភ្លេង ស្រុកល្វាឯម ខេត្តកណ្តាល

១- លោក មាន គាវ៉ុង
២- លោក ហេង គ្រា
៣- លោក រិន ពន្លក
៤- លោក មួន ចាសនា

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពាទស.១២០៥.៤៦៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២

លេខ: ៤៣៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១២
[illegible]រដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពល-ខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសភាពការណ៍ និងសំណូមពរចាំបាច់នៃការងារអភិវឌ្ឍន៍យោធា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១** : ត្រូវបានបង្កើតនាយកដ្ឋានអភិវឌ្ឍន៍ចំណុះផ្ទាល់ក្រសួងការពារជាតិ។

**មាត្រា ២** : នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ មានតួនាទីធ្វើជាសេនាធិការជូនក្រសួងការពារជាតិ ក្នុងវិស័យអភិវឌ្ឍន៍យោធា ដើម្បីកែប្រែជីវភាពរស់នៅរបស់កងទ័ព រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងមានភារកិច្ចដូចតទៅ :

- ដឹកនាំគ្រប់គ្រងស្ថាប័នអភិវឌ្ឍន៍ព្រមទាំងរោងចក្រ សហគ្រាស ក្រុមហ៊ុន សិប្បកម្ម កសិដ្ឋានចំណុះទាំងអស់នៃកងយោធពលខេមរភូមិន្ទតាមឋានានុក្រម ។

- ធ្វើផែនការមេអភិវឌ្ឍន៍វិស័យនានាមានកសិកម្ម កសិឧស្សាហកម្ម សិប្បកម្ម វារីវប្បកម្ម ជាដើម សម្រាប់អនុវត្តតាមតម្រូវការ និងលក្ខខណ្ឌជាក់ស្តែង (ភូមិសាស្ត្រ តម្រូវការទីផ្សារ លទ្ធភាពជាក់ស្តែង) ប្រកបដោយតម្លាភាព និងគណនេយ្យភាព រកចំណូលឲ្យបានច្រើន តាមដែលអាចធ្វើបាន រួមចំណែកលើកកម្ពស់ជីវភាពយោធិន នៃកងយោធពលខេមរភូមិន្ទ ទាំង ក្នុងអង្គភាព និងក្រៅអង្គភាព។
- គ្រប់គ្រងបានល្អ ចលន-អចលនទ្រព្យ ធនធានរបស់ស្ថាប័នអភិវឌ្ឍន៍ក្នុងកងយោធពល-ខេមរភូមិន្ទ។
- រួមចំណែកបណ្តុះបណ្តាលវិជ្ជាជីវៈ (ថ្នាក់មូលដ្ឋាន បឋម) នូវជំនាញកសិកម្ម សិប្បកម្ម។ល។ ដល់យោធិន ពិសេសយោធិនត្រៀមចូលនិវត្តន៍ និងយោធិនប្រភេទពីរ។
- សហការជាមួយបណ្តាសហគ្រាស ក្រុមហ៊ុន ស្ថាប័នរដ្ឋ និងឯកជន ជាតិ និងអន្តរជាតិ ធ្វើការ អភិវឌ្ឍន៍គម្រោងនានាដែលអាចធ្វើបានតាមច្បាប់រដ្ឋជាធរមាន។
- បូកសរុបរបាយការណ៍ស្តីពីលទ្ធផលការងារ នៃការអភិវឌ្ឍន៍ រាយការណ៍ជូនក្រសួងការ-ពារជាតិ។
- ពង្រឹង និងលើកកម្ពស់នូវវិន័យអត្តចរិត សីលធម៌រស់នៅ និងពង្រឹងកិត្យានុភាពរបស់កងទ័ព ឲ្យបានល្អប្រសើរ។
- ទទួលអនុវត្តនូវភារកិច្ចផ្សេងៗទៀតដែលក្រសួងការពារជាតិប្រគល់ឲ្យ។

នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិដឹកនាំដោយនាយកមួយរូប និងនាយករងបីរូប ជាជំនួយការ។

**មាត្រា ៣** : នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ មានរចនាសម្ព័ន្ធចាត់តាំងដូចតទៅ :

- នាយក
- នាយករង
- លេខាធិការដ្ឋាន
- ផ្នែកបុគ្គលិក
- ផ្នែកហិរញ្ញវត្ថុ
- ការិយាល័យផែនការ អប់រំ និងបណ្តុះបណ្តាល
- ការិយាល័យទំនាក់ទំនងសាធារណៈ
- ការិយាល័បច្ចេកទេស និងគ្រប់គ្រងសម្ភារៈ
- ការិយាល័យកសិកម្ម
- ការិយាល័យសិប្បកម្ម
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- កសិដ្ឋាន

ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចការិយាល័យនីមួយៗរបស់នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សច្ចាប័នៈ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២
បានឃើញ និងឯកភាព
លើរចនាសម្ព័ន្ធចាត់តាំងនាយកដ្ឋានអភិវឌ្ឍន៍
នៃក្រសួងការពារជាតិ
នាយករដ្ឋមន្ត្រី
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# រចនាសម្ព័ន្ធចាត់តាំង
## នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ
## ចំនួនរួម 134នាក់




បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- តាមសំណើ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១ :-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំង៖

-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ខណ្ឌឫស្សីកែវ និង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅភូមិអូរបែកក្អម សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានផ្ទៃដីទំហំសរុប ៣.៤១០ ម៉ែត្រក្រឡា។

-មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មានទីតាំងស្ថិតនៅភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានផ្ទៃដីទំហំសរុប ១២.៩២៣ ម៉ែត្រក្រឡា ។ ទីតាំងមជ្ឈមណ្ឌលយុវនីតិសម្បទាចោមចៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានទីតាំងនៅភូមិព្រៃកោង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានទំហំដី ១៩.៥៧២ម៉ែត្រក្រឡា។

-អគ្គនាយកដ្ឋានកៅស៊ូ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទីតាំងស្ថិតនៅឡូត៍លេខ ៥៨ ផ្លូវលេខ ៨៥ កែងផ្លូវលេខ ៣៩ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានដីទំហំសរុប ១.៨៥៣ ម៉ែត្រក្រឡា ។ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទីតាំងស្ថិតនៅឡូត៍លេខ៩ ផ្លូវលេខ២៨៩ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានដីទំហំ១.៣៩៩ម៉ែត្រក្រឡា។ អតីតការិយាល័យអ៊ីរី របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានទីតាំងស្ថិតនៅផ្លូវលេខ ៦៣ កែងផ្លូវលេខ ៤០០ ភូមិទី ៩ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានដីទំហំ ១.៣៥៨ម៉ែត្រក្រឡា។

-អគារប្រៃសណីយ៍ សាខាច្បារចំពៅ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានទីតាំងស្ថិតនៅសង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានដីទំហំ ៤៨៣ ម៉ែត្រក្រឡា។

**មាត្រា ២ :-**

ការលប់ទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សាលារាជធានីភ្នំពេញនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៣ :-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០០ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ** ជូន Federation of AEON Group Worker's Union ដែលបានមកបោះជំរុំការងារ ចំនួន ២២លើក និងជីកអណ្តូងទឹកស្អាត ចំនួន ៣០អណ្តូង ជូនប្រជាពលរដ្ឋ នៅតាមបណ្តាឃុំ-សង្កាត់ ក្នុងស្រុកទ្រាំង និងក្រុងដូនកែវ ខេត្តតាកែវ ចំណាយអស់ថវិកា សរុប ១៥៤.០០០ ដុល្លារអាមេរិក។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាល ខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃ [illegible] ២៧ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០១ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

### សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ធីង សុខុល** អនុមន្ត្រី ថ្នាក់លេខ ៣ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា ក្រសួងពត៌មាន ជំនួសលោក **ទូច ឆន្ធា** ដែលបានចូលនិវត្តន៍។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៦០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ៈ** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **អ៊ុយ សារឿន** អត្តលេខ ៦៧៩៨៥ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនអស់លោកជាម្ចាស់ជំនួយ-សហស្ថាបនិកអង្គការសម្រេចសុបិនកុមារចំនួន ០៤ នាក់ ដែលបានជួយកសាងសមិទ្ធិផលនានា និងសាលារៀនចំនួន ១១ ខ្នង នៅខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-លោក Daniel Macro Siegfried | សហស្ថាបនិកអង្គការសម្រេចសុបិនកុមារ |
| ២-លោក Eric Smit | ម្ចាស់ជំនួយអង្គការសម្រេចសុបិនកុមារ |
| ៣-លោក Marc Thomas Janni | សហស្ថាបនិកអង្គការសម្រេចសុបិនកុមារ |
| ៤-លោក Brad Crouch | ម្ចាស់ជំនួយអង្គការសម្រេចសុបិនកុមារ |

**មាត្រា ២** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ១ និងមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧០៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តកំពង់ឆ្នាំងចំនួន ១០ នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមាននាយនាមខាងក្រោម ៖

**ក- មេដាយមាសការងារ ៖**

| | |
|---|---|
| ១.លោក **គង់ សុវណ្ណអស្តារ្យ** | នាយករងទីចាត់ការសាលាខេត្តកំពង់ឆ្នាំង |
| ២-លោក **ចែម ភក្ត** | នាយករងរដ្ឋបាលសាលាស្រុកបរិបូណ៌ |
| ៣-លោក **ម៉ែន សិរី** | នាយករដ្ឋបាលសាលាក្រុងកំពង់ឆ្នាំង |

**ខ- មេដាយប្រាក់ការងារ ៖**

| | |
|---|---|
| ១-លោក **ជឹម យ៉េត** | នាយករងរដ្ឋបាលសាលាស្រុករលាប្អៀរ |
| ២-លោក **សូ ច័ន្ទធូ** | ប្រធានការិយាល័យសាលាស្រុករលាប្អៀរ |

**គ- មេដាយសំរឹទ្ធការងារ ៖**

| | |
|---|---|
| ១-លោក **ញ៉ែម ហ៊ីម** | អនុប្រធានការិយាល័យសាលាស្រុករលាប្អៀរ |

២-លោក **សួន ចន្ថា** ស្មៀនឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង
៣-លោក **ឈឹម ចស្សា** ស្មៀនឃុំអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង
៤-លោក **ម៉ាលី ពិសិដ្ឋ** ប្រធានការិយាល័យសាលាក្រុងកំពង់ឆ្នាំង
៥-លោក **ចក សុធា** ស្មៀនឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង

**ប្រការ ២** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ ឧសភា ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៦០៥ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១០០/២១៣ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការកែប្រែមាត្រា ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកែប្រែមាត្រា ៤ថ្មី នៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ ២០០៤ ស្តីពីការកែប្រែមាត្រា ៤ នៃ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

# ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានតែងតាំងឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី ជំនួសឯកឧត្តម **សួន សិរីឆ័** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងសាមីខ្លួន ដូចក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦០៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ **ធិបឌិន្ទ** ជូន លោក **សួន រីដា** មានគុណបំណាច់ខ្ពស់ និងស្នាដៃល្អក្នុងការចូលរួមកសាងសមិទ្ធផលនានា នៅវត្តប្រាសាទ ភូមិត្រពាំងសំរិទ្ធិ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ សម្រេចបានលទ្ធផលល្អប្រសើរ។

**មាត្រា ២.-**

